00649204

F16/3

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 03 / 03 / 2011
ម៉ោង (Time/Heure): 15:30
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Uch Arun

អង្គជំនុំជម្រះតុលាការកំពូល
Supreme Court Chamber
Chambre de la Cour suprême

សំណុំរឿងលេខ: ០០១/១៨ កក្កដា ២០០៧-អ.វ.ត.ក/អ.ជ.ត.ក
Case File/Dossier N°. 001/18-07-2007-ECCC/SC

នៅចំពោះមុខ៖

ចៅក្រម គង់ ស្រីម ប្រធាន
ចៅក្រម **Motoo NOGUCHI**
ចៅក្រម សោម សិរីវឌ្ឍ
ចៅក្រម **Agnieszka KLONOWIECKA MILART**
ចៅក្រម ស៊ិន រិទ្ធ
ចៅក្រម **Chandra Nihal Jayasinghe**
ចៅក្រម យ៉ា ណារិន

កាលបរិច្ឆេទឯកសារ៖ ថ្ងៃទី០៣ ខែមិនា ឆ្នាំ២០១១

ចំណាត់ថ្នាក់ឯកសារ៖ សាធារណៈ

# សេចក្តីសម្រេចស្តីពីសំណើរបស់អង្គភាពគាំពារការការពារក្តី សុំឲ្យអង្គជំនុំជម្រះតុលាការកំពូល អញ្ជើញភាគីទីបីដែលឯករាជ្យ ដាក់សារណារបស់អ្នកដែលមិនមែនជាភាគីក្នុងរឿងក្តី

**ផ្នែកគាំពារការការពារក្តី៖**

Nisha Valabhji
Rupert Abbott

**មេធាវីតំណាងភាគីដើមបណ្តឹងរដ្ឋប្បវេណីក្រុម១៖**

ទី ស្រីនណា
Karim KHAN

ផ្លូវជាតិលេខ ៤ សង្កាត់ ចោមចៅ ខ័ណ្ឌ ដង្កោ ក្រុងភ្នំពេញ កម្ពុជា ប្រអប់សំបុត្រ ៧១ ទូរស័ព្ទ: (៨៥៥)-២៣-២១៩-៨១៤ ទូរសារ: (៨៥៥)-២៣-២១៩-៨៤១ គេហទំព័រ: www.eccc.gov.kh
National Road 4, Chaom Chau, Dangkao, Phnom Penh, P.O. Box 71, Phnom Penh Tel:+855(0)23 219814 Fax:023 219841 Web: www.eccc.gov.kh

**<u>សហព្រះរាជអាជ្ញា៖</u>**

ជា លាង

Andrew CAYLEY

**<u>ជនជាប់ចោទ៖</u>**

កាំង ហ្គេកអ៊ាវ ហៅ "ឌុច"

**<u>សហមេធាវីការពារក្តីជនជាប់ចោទ</u>**

ការ សាវុត្ថ

កង ឫទ្ធារី

Alain WERNER
Brianne McGONIGLE

**<u>មេធាវីតំណាងភាគីដើមបណ្តឹងរដ្ឋប្បវេណីក្រុម២</u>**

គង់ ពិសី

ហុង គឹមសួន

យុង ផានិត

Silke STUDZINSKY

**<u>មេធាវីតំណាងភាគីដើមបណ្តឹងរដ្ឋប្បវេណីក្រុម៣</u>**

គឹម ម៉េងឃី

ម៉ុច សុវណ្ណារី

Martine JACQUIN
Annie DELAHAIE
Philippe CANONNE
Elizabeth RABESANDRATANA
Fabienne TRUSSES-NAPROUS
Christine MARTINEAU



E.C.C.C * C.E.T.C * SUPREME COURT CHAMBER CHAMBRE DE LA COUR SUPRÊME

**អង្គជំនុំជម្រះតុលាការកំពូល** នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា(“**អ.វ.ត.ក**”) បានទទួល “សំណើរបស់អង្គភាពគាំពារការពារក្ដីសុំឲ្យអង្គជំនុំជម្រះតុលាការកំពូល អនុវត្តសិទ្ធិអំណាចរបស់ខ្លួនតាមវិធាន៣៣នៃវិធានផ្ទៃក្នុងរបស់អ.វ.ត.ក” (“សំណើសុំ”)[1]។

## I. ប្រវត្តិនីតិវិធី

១. នៅថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ អង្គជំនុំជម្រះសាលាដំបូងនៃអ.វ.ត.ក បានចេញសាលក្រមប្រឆាំងនឹងជនជាប់ចោទ កាំង ហ្គេកអាវ *ហៅ* “ឌុច” (“សាលក្រមសាលាដំបូង”)[2]។ សហព្រះរាជអាជ្ញា ជនជាប់ចោទ និងដើមបណ្ដឹងរដ្ឋប្បវេណី ក្រុម ១ ២ និង ៣ បានដាក់បណ្ដឹងសាទុក្ខមកកាន់អង្គជំនុំជម្រះតុលាការកំពូលប្រឆាំងនឹងសាលក្រមនេះ[3]។

---

[1] ថ្ងៃទី២៨ ខែមករា ឆ្នាំ២០១១, F16

[2] E188 (កែតម្រូវ)។

[3] “ បណ្ដឹងសាទុក្ខបន្ទាន់របស់មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីក្រុម១ចំពោះការសម្រេចដកឋានៈជាដើមបណ្ដឹងរដ្ឋប្បវេណីចេញពីសាលក្រម,” ថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០១០, F8; សារណាបន្ថែមរបស់មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីក្រុម១ ចំពោះសេចក្ដីជូនដំណឹងអំពីគោលបំណង ថ្ងៃទី២៨ ខែតុលា ឆ្នាំ២០១០, F12; បណ្ដឹងសាទុក្ខរបស់សហមេធាវីតំណាង ដើមបណ្ដឹងរដ្ឋប្បវេណីក្រុម៣ ប្រឆាំងទៅនឹងសាលក្រម ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០, ថ្ងៃទី០៦ ខែតុលា ឆ្នាំ២០១០, F9; បណ្ដឹងសាទុក្ខរបស់សហព្រះរាជអាជ្ញាប្រឆាំងទៅនឹងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងសំណុំរឿង កាំង ហ្គេកអ៊ាវ ហៅ ឌុច, ចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១០, F10 (“សារណាបណ្ដឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា”); “សេចក្ដីជូនដំណឹងអំពីបណ្ដឹងសាទុក្ខរបស់សហមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី(ក្រុម២) និងទឡ្ហីករណ៍បណ្ដឹងសាទុក្ខប្រឆាំងនឹងសាលក្រម, ថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១០, E188/12; បណ្ដឹងសាទុក្ខប្រឆាំងនឹងការបដិសេធអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ក្នុងសាលក្រម, សហមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីក្រុម២, ថ្ងៃទី២២ ខែតុលា ឆ្នាំ២០១០,F11; បណ្ដឹងសាទុក្ខ ប្រឆាំងនឹងសាលក្រមស្ដីពីសំណងរបស់សហមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី ក្រុម២, ថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០១០, F13; សារណាបណ្ដឹងសាទុក្ខរបស់សហមេធាវីការពារក្ដីជនជាប់ចោទ កាំង ហ្គេកអ៊ាវ ហៅ “ឌុច” ប្រឆាំងនឹងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០, ថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០១០, F14 (“សារណាបណ្ដឹងសាទុក្ខ របស់ជនជាប់ចោទ”); សំណើសុំកែតម្រូវលើសារណាបណ្ដឹងសាទុក្ខរបស់ជនជាប់ចោទចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១០, F14/Corr-1; សំណើសុំកែតម្រូវលើសារណាបណ្ដឹងសាទុក្ខរបស់ជនជាប់ចោទ ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១១, F14/Corr-2; សារណាតបរបស់មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីក្រុម៣ ទៅនឹងបណ្ដឹងសាទុក្ខរបស់សហមេធាវីការពារក្ដីជនជាប់ចោទប្រឆាំងនឹងសាលក្រមចុះថ្ងៃទី៦ ខែកក្កដា ឆ្នាំ២០១០, ចុះថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០១០, F14/2; និងចម្លើយតបរបស់សហព្រះរាជអាជ្ញា

២. នៅថ្ងៃទី២៦ ខែមករា ឆ្នាំ២០១១ អង្គភាពគាំពារការការពារក្តីនៃអ.វ.ត.ក បានដាក់សំណើមកកាន់ក្រឡាបញ្ជីនៃអង្គជំនុំជម្រះតុលាការកំពូល ហើយសំណើនេះ ត្រូវបានដាក់ក្នុងសំណុំរឿង និងធ្វើការជូនដំណឹងនៅថ្ងៃទី២៨ ខែមករា ឆ្នាំ២០១១។ នៅថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០១១ សហព្រះរាជអាជ្ញា បានដាក់ចម្លើយតបរបស់ខ្លួនទៅនឹងសំណើនេះ(“ចម្លើយតប”)[4] និងនៅថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០១១ អង្គភាពគាំពារការការពារក្តី បានធ្វើការឆ្លើយតបទៅនឹងចម្លើយតបនេះ[5](“ការឆ្លើយតប”)។

## II. ផ្នែកសំអាងហេតុ

### ក.ច្បាប់ជាធរមាន

៣. វិធានផ្ទៃក្នុង(វិសោធនកម្មលើកទី ៦) ចែងថា៖

គ្រប់ដំណាក់កាលនីតិវិធី...

ប្រសិនបើពិចារណាឃើញថាមានលក្ខណៈចាំបាច់ខ្លាំងសម្រាប់ការជំនុំជម្រះលើរឿងក្តី អង្គជំនុំជម្រះ អាចអញ្ជើញ ឬ ផ្តល់ឱកាសឲ្យអង្គការ ឬ បុគ្គលណាមួយក្នុងការដាក់សារណារបស់អ្នកដែលមិនមែនជាភាគីក្នុងរឿងក្តីជាលាយលក្ខណ៍អក្សរ ពាក់ព័ន្ធនឹង

---

ទៅនឹងសារណាបណ្តឹងសាទុក្ខរបស់សហមេធាវីការពារក្តីជនជាប់ចោទ កាំង ហ្កេកអ៊ាវ ហៅ “ឌុច” ប្រឆាំងនឹងសាលក្រមសាលាដំបូងចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០, ថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១០, F14/4។ ចម្លើយតប របស់សហព្រះរាជអាជ្ញាទៅនឹងសារណាបណ្តឹងសាទុក្ខរបស់សហមេធាវីការពារក្តីជនជាប់ចោទ កាំង ហ្កេក អ៊ាវ ហៅ ឌុច ប្រឆាំងនឹងសាលក្រមអង្គជំនុំជម្រះសាលាដំបូងចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០, ថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១០, F14/4; ការឆ្លើយ តបរបស់សហមេធាវីការពាក្តីជនជាប់ចោទ ទៅនឹងចម្លើយតបរបស់សហព្រះរាជអាជ្ញា ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១០, ថ្ងៃទី១៤ ខែមករា ឆ្នាំ២០១១, F14/2។

[4] សេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាសុំពន្យារពេលឆ្លើយតបទៅនឹងសារណាបណ្តឹងសាទុក្ខរបស់ជនជាប់ចោទ ចុះថ្ងៃទី ០៧ ខែធ្នូ ឆ្នាំ២០១០ F14/3; សំណើរបស់សហព្រះរាជអាជ្ញាសុំពន្យារពេលដាក់ចម្លើយតបទៅនឹងសារណាបណ្តឹងសាទុក្ខរបស់សហមេធាវីការពារជនជាប់ចោទ កាំង ហ្កេកអ៊ាវ ហៅ “ឌុច” ប្រឆាំងនឹងសាលក្រមអង្គជំនុំជម្រះសាលាដំបូងចុះថ្ងៃទី ២៦ ខែកក្កដា ឆ្នាំ២០១០, ថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០១០, F14/1។

[5] ការឆ្លើយតបរបស់អង្គភាពគាំពារការការពារក្តី ទៅនឹងចម្លើយតបរបស់សហព្រះរាជអាជ្ញាចំពោះសំណើ របស់អង្គភាពគាំពារការការពារក្តីដែលសុំឲ្យអង្គជំនុំជម្រះតុលាការកំពូលអនុវត្តសិទ្ធិអំណាចរបស់ខ្លួនតាម វិធាន៣៣នៃវិធានផ្ទៃក្នុង F16/2។

**សេចក្តីសម្រេចស្តីពីសំណើរបស់អង្គភាពគាំពារការការពារក្តី សុំឲ្យអង្គជំនុំជម្រះតុលាការកំពូល អញ្ជើញភាគីទីបី[illegible] ដាក់សារណារបស់អ្នកដែលមិនមែនជាភាគីក្នុងរឿងក្តី**

បញ្ហាណាមួយ... អង្គជំនុំជម្រះដែលពាក់ព័ន្ធនោះ ត្រូវកំណត់ពេលវេលា ក្នុងការដាក់ឯកសារនៃសារណានេះ ប្រសិនបើមាន។

...

សារណារបស់អ្នកដែលមិនមែនជាភាគីក្នុងរឿងក្តីតាមវិធាននេះ ត្រូវដាក់នៅក្រឡាបញ្ជីនៃអង្គជំនុំជម្រះពាក់ព័ន្ធ ហើយក្រឡាបញ្ជីត្រូវថតចម្លងជូនទៅសហព្រះរាជអាជ្ញា និងមេធាវីរបស់ភាគីដ៏ទៃទៀតដែលត្រូវបានផ្តល់ឱកាសក្នុងការឆ្លើយតប[6]។

## III. អង្គសេចក្តី

៤. នៅក្នុងសំណើនេះ អង្គភាពគាំពារការការពារក្តី ស្នើសុំអង្គជំនុំជម្រះតុលាការកំពូល អញ្ជើញភាគីទីបីដែលឯករាជ្យ ឱ្យដាក់សារណាមួយ ឬ ច្រើនរបស់អ្នកដែលមិនមែនជាភាគីក្នុងរឿងក្តី ក្នុងគោលបំណងដើម្បីធានានូវ"អំណះអំណាងផ្នែកច្បាប់ទាក់ទងនឹងបញ្ហានានាដែលលើកឡើងក្នុងបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា ហើយមកដល់ពេលនេះ មិនត្រូវបានលើកឡើងដោយសហមេធាវីការពារក្តីនៅក្នុងដំណើរការនីតិវិធី ជាពិសេស បញ្ហាស្តីពីការកំណត់ទោស"[7]។ សហព្រះរាជអាជ្ញា គាំទ្រការអញ្ជើញរបស់អង្គជំនុំជម្រះតុលាការកំពូល ស្របតាមវិធាន ៣៣(១) នៃវិធានផ្ទៃក្នុងថា កម្រិតត្រឹមតែ" សារណាដែលមានលក្ខណៈឯករាជ្យនិងឥតលំអៀង " របស់ "ភាគីដែលមានលក្ខណៈឯករាជ្យសមស្រប" ប្រសិនបើអង្គជំនុំជម្រះយល់ថា សារណានេះ អាចជួយក្នុងការពិចារណារបស់ខ្លួនលើបញ្ហាដែលលើកឡើងដោយភាគីនានាទៅលើបណ្តឹងសាទុក្ខ[8]។

៥. យោងតាមហេតុផលខាងក្រោម អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា វាពុំមានលក្ខណៈសមស្របក្នុងការអញ្ជើញការដាក់សារណារបស់អ្នកដែលមិនមែនជាភាគីនៃរឿងក្តីតាមវិធាន៣៣(១)។

---

[6] វិធាន៣៣(១)-(២)នៃវិធាផ្ទៃក្នុង។

[7] សំណើសុំ កថាខណ្ឌ១៦។

[8] ចម្លើយតប កថាខណ្ឌ៥។

៦. ចំនុចទីមួយ អង្គជំនុំជម្រះតុលាការកំពូល ត្រូវគោរពយុទ្ធសាស្ត្របណ្តឹងសាទុក្ខ ដែលបានជ្រើសរើសដោយសហមេធាវីជាតិពីររូប ដែលជ្រើសរើសដោយជនជាប់ចោទស្របតាមវិធានផ្ទៃក្នុង[9]។ ជនជាប់ចោទ និងសហមេធាវី មិនតម្រូវឱ្យដាក់ចម្លើយតបជាលាយលក្ខណ៍អក្សរទៅនឹងសារណាបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា និងមិនតម្រូវឱ្យបង្ហាញជាសាធារណៈនូវមូលហេតុដែលខ្លួន "ជ្រើសរើសមិនធ្វើការឆ្លើយតប"នោះទេ[10]។

៧. ចំនុចទីពីរ វាមិនមានលក្ខណៈត្រឹមត្រូវដែលអង្គភាពគាំពារការការពារក្តីពោលថា មកដល់ពេលនេះ សហមេធាវីរបស់ជនជាប់ចោទ បានផ្តោតទាំងស្រុងតែលើ"បញ្ហាយុត្តាធិការបុគ្គលក្នុងនីតិវិធីបណ្តឹងសាទុក្ខ"[11]នោះប៉ុណ្ណោះទេ។ ឧទាហរណ៍ ជនជាប់ចោទ បានដាក់ពាក្យបណ្តឹងប្រឆាំងនឹងការដាក់ទោសដោយសំអាងថា អង្គជំនុំជម្រះសាលាដំបូងខកខានមិនបាន " យោងទៅលើប្បញ្ញត្តិនៃមាត្រា៩៥នៃក្រមព្រហ្មទណ្ឌកម្ពុជាបច្ចុប្បន្ន"[12]។

៨. ចំនុចទីបី អង្គភាពគាំពារការការពារក្តី យល់ឃើញត្រឹមត្រូវថា សហមេធាវីជនជាប់ចោទកន្លងមក មិនបានលើកក្នុងបណ្តឹងជាលាយលក្ខណ៍អក្សររបស់ខ្លួននូវទឡ្ហីករណ៍ជាក់លាក់នៃសារណាបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញាទាក់ទងនឹងការកំណត់ទោស និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិទេ។ យុទ្ធសាស្ត្របណ្តឹងសាទុក្ខដែលសហមេធាវីការពារក្តីជនជាប់ចោទជ្រើសរើសនេះ មិនមានន័យថា បើគ្មានការអញ្ជើញឱ្យដាក់សារណារបស់អង្គជំនុំជម្រះតុលាការកំពូលតាមវិធាន៣៣(១)នៃវិធានផ្ទៃក្នុងទេនោះ "ការលើកឡើងយ៉ាងពេញលេញ"នៃសារណាបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា គឺ "ទំនងជាមិនអាចកើតមាននោះទេ"[13] ។ ចៅក្រមអង្គជំនុំជម្រះតុលាការកំពូល ត្រូវបានចងភ្ជាប់កាតព្វកិច្ច ក្នុងការធ្វើការពិចារណាគ្រប់ជ្រុងជ្រោយរាល់សារណាបណ្តឹងសាទុក្ខទាំងអស់ រួមទាំងសារណារបស់សហព្រះរាជអាជ្ញាផងដែរ។

---

[9] សូមមើល " ទម្រង់ទី៧០: សំណើសុំចាត់តាំងសហមេធាវី " ថ្ងៃទី២០ កក្កដា ឆ្នាំ២០១០, E189.2 ( ក្នុងនោះ ជនជាប់ចោទស្នើសុំការតំណាងការពារក្តីរបស់លោក កង ឫទ្ធារី។

[10] សំណើសុំ កថាខណ្ឌ ៧, សូមមើលចម្លើយតបកថាខណ្ឌ២។

[11] បទបញ្ជាតុលាការ, ICC-BD/01-02-07, ថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០០៤ (ធ្វើវិសោធនកម្ម) បទបញ្ជាតុលាការ ២៤(៥), ៦០(១)។

[12] សារណាបណ្តឹងសាទុក្ខរបស់ជនជាប់ចោទ កថាខណ្ឌ៩១។

[13] សំណើសុំ កថាខណ្ឌ៩។



E.C.C.C * C.E.T.C
SUPREME COURT CHAMBER CHAMBRE DE LA COUR SUPREME

៩. ចំណុចទីបួន អង្គជំនុំជម្រះតុលាការកំពូល ត្រូវគោរពសិទ្ធិរបស់ជនជាប់ចោទក្នុងការជំរុញឱ្យដំណើរការនីតិវិធី"ឈានដល់ទីបញ្ចប់តាមពេលសមស្រប"[14]។ ក្នុងដំណាក់នៃបណ្តឹងសាទុក្ខនេះ អង្គជំនុំជម្រះពិចារណាឃើញថា វាអាចបង្កនូវការយឺតយ៉ាវមិនសមហេតុផលក្នុងការអញ្ជើញអង្គការណាមួយ ឬ បុគ្គលណាម្នាក់ជាសាធារណៈ ឬ ស្នើសុំឱ្យស្រាវជ្រាវ និងអញ្ជើញអង្គការជាក់លាក់ណាមួយ ឬ បុគ្គលណាមួយឱ្យដាក់សារណារបស់អ្នកដែលមិនមែនជាភាគីនៃរឿងក្តី ហើយបន្ទាប់មករង់ចាំការដាក់សារណានេះ។ ការពិចារណានេះ មិនមានការប៉ះពាល់ដល់លទ្ធភាពដែលអាចធ្វើបានចំពោះអង្គការ ឬ បុគ្គលណាមួយ ដែលអាចដាក់សំណើមកកាន់អង្គជំនុំជម្រះតុលាការកំពូល តាមវិធាន៣៣(១) សុំការអនុញ្ញាតដាក់នូវសារណារបស់អ្នកដែលមិនមែនជាភាគីនៃរឿងក្តីស្តីអំពីការកំណត់ទោស និង/ឬ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនោះទេ។ អង្គជំនុំជម្រះតុលាការកំពូល យល់ឃើញថា មិនមានបទប្បញ្ញត្តិណាមួយនៅក្នុងកិច្ចព្រមព្រៀងអ.វ.ត.ក ច្បាប់អ.វ.ត.ក ឬ វិធានផ្ទៃក្នុងដែលរារាំងមិនឱ្យអង្គភាពគាំពារការការពារក្តី ធ្វើការស្វះស្វែងបញ្ជាក់នូវអង្គការ ឬ បុគ្គលមិនជាប់ពាក់ព័ន្ធជាផ្លូវការជាមួយអ.វ.ត.ក[15]ដែលមានបំណងផ្តល់នូវសារណាបែបនេះសំរាប់អង្គជំនុំជម្រះធ្វើការពិចារណានោះទេ។

១០. ដោយសារតែអានុភាពបូកបញ្ចូលគ្នានៃហេតុផលទាំងនេះហើយ ទើបអង្គជំនុំជម្រះតុលាការកំពូលសម្រេចច្រានចោលសំណើនេះ។ ដូច្នេះ អង្គជំនុំជម្រះ ពុំចាំបាច់ធ្វើការពិចារណាលើភាពខ្វែងគំនិតគ្នារវាងអង្គភាពគាំពារការការពារក្តី និងសហព្រះរាជអាជ្ញាដែលថា តើ "នៅពេលដែលដំណោះស្រាយនេះ បម្រើប្រយោជន៍នៃយុត្តិធម៌នោះ អង្គជំនុំជម្រះ មានឆន្ទានុសិទ្ធិក្នុងការស្នើសុំអ្នកដែលមិនមែនជាភាគីនៃរឿងក្តីឱ្យលើកឡើងជាប្រយោជន៍ដល់ភាគីណាមួយ ដែរឬទេ" [16] នោះឡើយ ។

## IV. ផ្នែកសម្រេចសេចក្តី

**យោងតាមមូលហេតុដែលបានលើកឡើងខាងលើ អង្គជំនុំជម្រះតុលាការកំពូលសម្រេចជាឯកច្ឆន្ទៈ**

---

[14] វិធាន២១(៤)នៃវិធានផ្ទៃក្នុង។

[15] សេចក្តីសម្រេចលើសំណើរបស់អង្គភាពគាំពារការការពារក្តី សុំដាក់សារណារបស់អ្នកដែលមិនមែនជាភាគីក្នុងរឿងក្តីមកកាន់អង្គជំនុំជម្រះតុលាការកំពូល ថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១០, F7/2, កថាខណ្ឌ៩។

[16] សំណើសុំ កថាខណ្ឌ១១។ សូមមើលចម្លើយតប កថាខណ្ឌ៣-៤ និងការឆ្លើយតប កថាខណ្ឌ ៨-១៤។



SUPREME COURT CHAMBER CHAMBRE DE LA COUR SUPREME * C.C.C * C.E.T.C *

សំណើសុំនេះត្រូវបានបដិសេធចោលជាអសារបង់។

**រាជធានីភ្នំពេញ ថ្ងៃទី០៣ ខែមិនា ឆ្នាំ២០១១**

**ប្រធានអង្គជំនុំជម្រះតុលាការកំពូល**

**គង់ ស្រ៊ឹម**